ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០៣១/២៣ គជបជ

សូមគោរពជូន
សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**កម្មវត្ថុ៖** សូមគោរពជូន របាយការណ៍សកម្មភាព និងលទ្ធផលសង្ខេប ស្តីពីការងារសំខាន់ៗ ក្នុងការដឹកនាំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅដើមឆ្នាំ២០២៣ ។

លេខ: 6៤1 ថ្ងៃ: ៣-០២-២៣

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មេត្តាជ្រាបថា៖ ក្នុងនាមជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំបានបំពេញភារកិច្ច ក្នុងការដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

១. ការរៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សរវាង ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ បានឈានដល់ការចុះហត្ថលេខា នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២នេះ នាទីក្រុងបាងកក ដែលមាននាងខ្ញុំជាតំណាងភាគីកម្ពុជា ជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (ដោយទទួលបានសិទ្ធិប្រទាន ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី**) និងលោកជំទាវរដ្ឋលេខា ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ជាតំណាងភាគីថៃ ។

២. ផែនការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ៖ ភាគីទាំងពីរ កម្ពុជា-ថៃ បានឯកភាពបន្តការពិភាក្សា លើការរៀបចំផែនការសកម្មភាពសម្រាប់ អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី១៦ ដល់ទី១៩ ខែមករា ឆ្នាំ២០២៣ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា ដែលក្នុងឱកាសនោះ មានការពិភាក្សាលើផ្នែកចំនួនពីរ៖

ក. ការរៀបចំផែនការអនុវត្ត នីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីការតាមដានករណី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដែលបានចុះហត្ថលេខារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ថៃ ពីឆ្នាំ២០១៩។

ខ. ការរៀបចំផែនការអនុវត្ត នីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ដែលបានចុះហត្ថលេខាដោយ គណៈកម្មាធិការជាតិប្រយុទ្ធ

ប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ថៃ នៅខែសីហា ឆ្នាំ២០២២។

ជាលទ្ធផល សេចក្តីព្រាងដែលភាគីកម្ពុជាបានរៀបចំ ត្រូវបានគណៈប្រតិភូថៃ ឯកភាពទទួលយកស្ទើរទាំងស្រុងហើយ តែស្នើសុំយកទៅប្រជុំរកធាតុចូលបន្ថែមពីក្រសួងពាក់ព័ន្ធសិន និងស្នើសុំជួបជាថ្មីនៅដើមខែមិថុនា ឆ្នាំ២០២៣ ដើម្បីចុះហត្ថលេខាសម្រេច នៅឯទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។ ភាគីទាំងពីរ ឯកភាព ជួបពិភាក្សាលើការអនុវត្តជាក់ស្តែង ២ដងក្នុងមួយឆ្នាំ ដោយធ្វើការប្តូរវេណ ក្នុងការរៀបចំ ។ ដំណើរការនេះត្រូវបានគាំទ្រដោយ អង្គការ IOM ។

៣. នៅថ្ងៃទី៩ និងទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ នាងខ្ញុំបានទទួលការអនុញ្ញាតពី សម្តេចក្រឡាហោម ដើម្បីដឹកនាំគណៈប្រតិភូ មួយរូប (លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ ទៅចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៃសន្និសីទបាលីប្រូសេស ដែលមានវេទិការដ្ឋាភិបាល និងវិស័យឯកជន ពិភាក្សាអំពីទម្រង់ថ្មី នៃអំពើរត់ពន្ធមនុស្ស ការប្រើពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស (Bali Process Conference: the Government and Business Forum on People Smuggling, Forced Labor and Trafficking in persons) ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើប និងពិបាកស្វែងរកជនល្មើសដើម្បីផ្តន្ទាទោស ។

លោកជំទាវរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី និងលោកជំទាវ រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូណេស៊ី ជាអ្នកដឹកនាំកម្មវិធីដូចរាល់ឆ្នាំ ។ នៅក្នុងសេចក្តីថ្លែងការណ៍ លោកជំទាវ រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូណេស៊ី មិនភ្លេចនឹងថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះ ជាពិសេសប្រជាជនឥណ្ឌូណេស៊ី ពីក្នុងបទល្មើស Game Scam ។

គោលគំនិតក្នុងកិច្ចប្រជុំនេះគឺ លើកកម្ពស់កិច្ចសហការក្នុងការឆ្លើយតប ទៅនឹងទម្រង់ថ្មីនៃបទល្មើស ពីគ្រប់ភាគីពាក់ព័ន្ធ ទាំងរដ្ឋាភិបាល វិស័យឯកជន និងអង្គការដៃគូ លើការបង្ការទប់ស្កាត់ និងលុបបំបាត់អំពើ រត់ពន្ធមនុស្ស ការងារដោយបង្ខំ និងអំពើជួញដូរមនុស្ស ដែលកំពុងតែរីករាលដាលទូទាំងក្នុងតំបន់ រួមជាមួយការប្រើប្រាស់ប្រព័ន្ធអនឡាញ។

នៅក្នុងឱកាសនោះដែរ គណៈប្រតិភូប្រទេសស្រីលង្កា ដឹកនាំដោយ ឯកឧត្តម Thuraya Balasuriya រដ្ឋមន្ត្រីក្រសួងការបរទេស បានសុំជួបពិភាក្សាអំពីទំនាក់ទំនងកិច្ចសហការរវាងកម្ពុជាស្រីលង្កា ដែលគោលគំនិតសំខាន់ គឺចង់ពង្រឹងទំនាក់ទំនងជាថ្មី តាមរយៈការផ្លាស់ប្តូរ គណៈប្រតិភូព្រះសង្ឃក្នុងវិស័យពុទ្ធសាសនា និងពង្រឹងទំនាក់ទំនងផ្នែកវិហារពុទ្ធសាសនា ការសិក្សាអប់រំ វិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្មដទៃទៀត ។ ជាការឆ្លើយតប នាងខ្ញុំបានជម្រាបវិញថា

នាងខ្ញុំនឹងគោរពរាយការណ៍ជូនថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល ដើម្បីជូនជ្រាប និងទំនាក់ទំនងដោយផ្ទាល់ ។

ទន្ទឹមនឹងនោះ លោក David និងកញ្ញា Rose ដែលជា ការិយាល័យគាំទ្រថ្នាក់តំបន់ របស់Bali Process ដែលមានការិយាល័យ នៅទីក្រុងបាងកក បានជួយពិភាក្សា លើសេចក្តីត្រូវការក្នុងការគាំទ្រពី Bali Process ជាពិសេស ការបណ្តុះបណ្តាលមន្ត្រីមានសមត្ថកិច្ច អំពីជំនាញពាក់ព័ន្ធនឹង ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឬការងារពាក់ព័ន្ធនឹងវិធានការផ្សេងៗ ជាកិច្ចសហការក្នុងតំបន់ជាដើម ។ ក្នុងករណីនេះ នាងខ្ញុំបានជម្រាបពីសេចក្តីត្រូវការ ក្នុងការកំណត់គោលការណ៍រួម ដើម្បីកំណត់បទល្មើសជាពិសេសបទល្មើសទម្រង់ថ្មី ដែលមានការរួមផ្សំពីបទល្មើសដទៃទៀត ដូចជាករណីបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ (Online Scaming) ឬ ករណីរំលោភបំពានតាមប្រព័ន្ធអនឡាញផ្សេងទៀត ដែលមិនមែនជាករណីជួញដូរមនុស្សទាំងអស់នោះទេ ដូច្នេះការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ ជារឿងសំខាន់សម្រាប់កិច្ចសហការរវាងប្រទេសពាក់ព័ន្ធនៅពេលមានបទល្មើស ដែលកើតឡើងក្នុងប្រទេសណាមួយ និងមានជនបរទេសជាជនរងគ្រោះ ឬជាជនល្មើស ។

៤. តាមសំណើឯកឧត្តម SHIN Ja Yong អនុរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ទទួលបន្ទុកកិច្ចរដ្ឋអាជ្ញា នៃសាធារណរដ្ឋកូរ៉េ ឲ្យមានអនុស្សរណៈរួមគ្នា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំបានដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយកដ្ឋានពាក់ព័ន្ធ ក្រសួងការបរទេស ក្រសួងយុត្តិធម៌ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យលើខ្លឹមសារនៃសារលិខិត និងប្រមូលទិន្នន័យ ពាក់ព័ន្ធនឹងស្ថានភាពនៃទំនាក់ទំនងវិស័យការងារ ទេសចរណ៍ និងពលករ រវាងកម្ពុជា កូរ៉េ និងសម្រេចគោរពស្នើសុំគោលការណ៍ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដើម្បីជួបពិភាក្សាជាមួយភាគីកូរ៉េ លើខ្លឹមសារសេចក្តីព្រាងអនុស្សរណៈ ដែលបានស្នើ។

៥. សាធារណរដ្ឋឥណ្ឌា បានព្រាងនូវអនុស្សរណៈថ្មីមួយ សម្រាប់កិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារពាក់ព័ន្ធនឹងការសម្របសម្រួល ក្នុងការអនុញ្ញាតឲ្យមានភាពចល័ត នៃពលរដ្ឋឥណ្ឌា រួមមានពលរដ្ឋសាមញ្ញ និស្សិត អ្នកស្រាវជ្រាវ អ្នកជំនួញ អ្នកទេសចរណ៍ អ្នកមកធ្វើការងារជាដើម នៅក្នុងប្រទេសកម្ពុជា និងពលរដ្ឋកម្ពុជា ដែលនៅក្នុងប្រទេសឥណ្ឌា រួមមានការទទួលបានសេវា សិទ្ធិក្នុងការស្នាក់នៅ និងការបញ្ជូនជនរងគ្រោះ ។ល។

ក្នុងបរិបទនេះនាងខ្ញុំពិនិត្យឃើញថា ចាំបាច់ត្រូវស្វែងរក និងប្រមូលទិន្នន័យ ពាក់ព័ន្ធនឹងពលរដ្ឋឥណ្ឌានៅកម្ពុជា និងស្ថានភាព ឬបញ្ហាផ្សេងៗ ដែលមានកន្លងមកជាមុនសិន និងពិនិត្យលទ្ធភាពក្នុងកិច្ចសហការ ដោយថ្លឹងថ្លែងលើផលប៉ះពាល់ ដែលមិនជះឥទ្ធិពលដល់សុវត្ថិភាព សន្តិសុខ

សេដ្ឋកិច្ច និងនយោបាយការបរទេស ។ នាងខ្ញុំបារម្ភថា កន្លងមកឥណ្ឌា មានអ្នកជំនាញបច្ចេកទេសខាងបង្កើត និងគ្រប់គ្រង កម្មវិធីតាមប្រព័ន្ធឌីជីថល ជាពិសេសក្នុងប្រព័ន្ធ Game Scamming យ៉ាងប៉ិនប្រសប់ និងទទួលបានប្រាក់កម្រៃខ្ពស់ ។ យើងបារម្ភថា ក្រុមនេះ អាចក្លាយជាក្រុមដែលប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា ដែលយើងមិនទាន់មានសមត្ថភាពគ្រប់គ្រងបាន ។

កន្លងមក ព្រះរាជាណាចក្រកម្ពុជា និងឥណ្ឌា ធ្លាប់មានអនុស្សរណៈ សម្រាប់បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចុះហត្ថលេខា ពីឆ្នាំ២០១៨ រួចហើយ តែមិនទាន់បានជជែកគ្នាអំពីការអនុវត្តទាល់តែសោះ ។ ដើម្បីមានមូលដ្ឋាន ក្នុងការជជែកពិភាក្សាលើអនុស្សរណៈថ្មីដែលស្នើឡើង នាងខ្ញុំសូមគោរពស្នើសុំគោលការណ៍ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង និងអង្គភាពជំនាញពាក់ព័ន្ធ រួមមាន៖ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម ដើម្បីត្រៀមចំណុចសំខាន់ៗសម្រាប់ពិភាក្សាសេចក្តីព្រាងអនុស្សរណៈ មុននឹងពិភាក្សាជាមួយភាគីឥណ្ឌា ។

**ទិសដៅបន្ត ៖**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៣ និងរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំបន្ត (២០២៤-២០២៨) ដោយដាក់បញ្ចូលនូវបញ្ហាជាអាទិភាព ដែលប្រឈមចំពោះមុខពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសទម្រង់ថ្មីៗ នៃបទល្មើសជួញដូរមនុស្ស ដែលផ្សារភ្ជាប់ជាមួយទម្រង់ផ្សេងទៀត នៃឧក្រិដ្ឋកម្មឆ្លងដែន និងបច្ចេកវិទ្យាព័ត៌មាន ។

អាស្រ័យដូចបានគោរពរាយការណ៍ជូនខាងលើសូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃពុធ ១០រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០៣១/២៣ គ.ជ.ប.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**កម្មវត្ថុ៖** សូមគោរពជូន របាយការណ៍សកម្មភាព និងលទ្ធផលសង្ខេប ស្តីពីការងារសំខាន់ៗ ក្នុងការដឹកនាំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅដើមឆ្នាំ២០២៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហារផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មេត្តាជ្រាបថា៖ ក្នុងនាមជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំបានបំពេញភារកិច្ច ក្នុងការដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

១. ការរៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សរវាង ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ បានឈានដល់ការចុះហត្ថលេខា នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២នេះ នាទីក្រុងបាងកក ដែលមាននាងខ្ញុំជាតំណាងភាគីកម្ពុជា ជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (ដោយទទួលបានសិទ្ធិប្រទាន ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី**) និងលោកជំទាវរដ្ឋលេខា ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ជាតំណាងភាគីថៃ ។

២. ផែនការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ៖ ភាគីទាំងពីរ កម្ពុជា-ថៃ បានឯកភាពបន្តការពិភាក្សា លើការរៀបចំផែនការសកម្មភាពសម្រាប់ អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី១៦ ដល់ទី១៩ ខែមករា ឆ្នាំ២០២៣ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា ដែលក្នុងឱកាសនោះ មានការពិភាក្សាលើផ្នែកចំនួនពីរ៖

ក. ការរៀបចំផែនការអនុវត្ត នីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីការតាមដានករណី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដែលបានចុះហត្ថលេខារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ថៃ ពីឆ្នាំ២០១៩។

ខ. ការរៀបចំផែនការអនុវត្ត នីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ដែលបានចុះហត្ថលេខាដោយ គណៈកម្មាធិការជាតិប្រយុទ្ធ

ប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ថៃ នៅខែសីហា ឆ្នាំ២០២២។

ជាលទ្ធផល សេចក្តីព្រាងដែលភាគីកម្ពុជាបានរៀបចំ ត្រូវបានគណៈប្រតិភូថៃ ឯកភាពទទួលយកស្ទើរទាំងស្រុងហើយ តែស្នើសុំយកទៅប្រជុំរកធាតុចូលបន្ថែមពីក្រសួងពាក់ព័ន្ធសិន និងស្នើសុំជួបជាថ្មីនៅដើមខែមិថុនា ឆ្នាំ២០២៣ ដើម្បីចុះហត្ថលេខាសម្រេច នៅឯទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។ ភាគីទាំងពីរ ឯកភាព ជួបពិភាក្សាលើការអនុវត្តជាក់ស្តែង ២ដងក្នុងមួយឆ្នាំ ដោយធ្វើការប្តូរវេណ ក្នុងការរៀបចំ ។ ដំណើរការនេះត្រូវបានគាំទ្រដោយ អង្គការ IOM ។

៣. នៅថ្ងៃទី៩ និងទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ នាងខ្ញុំបានទទួលការអនុញ្ញាតពី សម្តេចក្រឡាហោម ដើម្បីដឹកនាំគណៈប្រតិភូ មួយរូប (លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុក ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ ទៅចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៃសន្និសីទបាលីប្រូសេស ដែលមានវេទិការដ្ឋាភិបាល និងវិស័យឯកជន ពិភាក្សាអំពីទម្រង់ថ្មី នៃអំពើរត់ពន្ធមនុស្ស ការប្រើពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស (Bali Process Conference: the Government and Business Forum on People Smuggling, Forced Labor and Trafficking in persons) ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើប និងពិបាកស្វែងរកជនល្មើសដើម្បីផ្តន្ទាទោស ។

លោកជំទាវរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី និងលោកជំទាវ រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូណេស៊ី ជាអ្នកដឹកនាំកម្មវិធីដូចរាល់ឆ្នាំ ។ នៅក្នុងសេចក្តីថ្លែងការណ៍ លោកជំទាវ រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូណេស៊ី មិនភ្លេចនឹងថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះ ជាពិសេសប្រជាជនឥណ្ឌូណេស៊ី ពីក្នុងបទល្មើស Game Scam ។

គោលគំនិតក្នុងកិច្ចប្រជុំនេះគឺ លើកកម្ពស់កិច្ចសហការក្នុងការឆ្លើយតប ទៅនឹងទម្រង់ថ្មីនៃបទល្មើស ពីគ្រប់ភាគីពាក់ព័ន្ធ ទាំងរដ្ឋាភិបាល វិស័យឯកជន និងអង្គការដៃគូ លើការបង្ការទប់ស្កាត់ និងលុបបំបាត់អំពើ រត់ពន្ធមនុស្ស ការងារដោយបង្ខំ និងអំពើជួញដូរមនុស្ស ដែលកំពុងតែរីករាលដាលទូទាំងក្នុងតំបន់ រួមជាមួយការប្រើប្រាស់ប្រព័ន្ធអនឡាញ។

នៅក្នុងឱកាសនោះដែរ គណៈប្រតិភូប្រទេសស្រីលង្កា ដឹកនាំដោយ ឯកឧត្តម Thuraya Balasuriya រដ្ឋមន្ត្រីក្រសួងការបរទេស បានសុំជួបពិភាក្សាអំពីទំនាក់ទំនងកិច្ចសហការរវាងកម្ពុជា ស្រីលង្កា ដែលគោលគំនិតសំខាន់ គឺចង់ពង្រឹងទំនាក់ទំនងជាថ្មី តាមរយៈការផ្លាស់ប្តូរ គណៈប្រតិភូព្រះសង្ឃក្នុងវិស័យពុទ្ធសាសនា និងពង្រឹងទំនាក់ទំនងផ្នែកវិហារពុទ្ធសាសនា ការសិក្សាអប់រំ វិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្មដទៃទៀត ។ ជាការឆ្លើយតប នាងខ្ញុំបានជម្រាបវិញថា

នាងខ្ញុំនឹងគោរពរាយការណ៍ជូនថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល ដើម្បីជូនជ្រាប និងទំនាក់ទំនងដោយផ្ទាល់ ។

ទន្ទឹមនឹងនោះ លោក David និងកញ្ញា Rose ដែលជា ការិយាល័យគាំទ្រថ្នាក់តំបន់ របស់Bali Process ដែលមានការិយាល័យ នៅទីក្រុងបាងកក បានជួយពិភាក្សា លើសេចក្តីត្រូវការក្នុងការគាំទ្រពី Bali Process ជាពិសេស ការបណ្តុះបណ្តាលមន្ត្រីមានសមត្ថកិច្ច អំពីជំនាញពាក់ព័ន្ធនឹង ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឬការងារពាក់ព័ន្ធនឹងវិធានការផ្សេងៗ ជាកិច្ចសហការក្នុងតំបន់ជាដើម ។ ក្នុងករណីនេះ នាងខ្ញុំបានជម្រាបពីសេចក្តីត្រូវការ ក្នុងការកំណត់គោលការណ៍រួម ដើម្បីកំណត់បទល្មើស ជាពិសេសបទល្មើសទម្រង់ថ្មី ដែលមានការរួមផ្សំពីបទល្មើសដទៃទៀត ដូចជាករណីបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ (Online Scaming) ឬ ករណីរំលោភបំពានតាមប្រព័ន្ធអនឡាញផ្សេងទៀត ដែលមិនមែនជាករណីជួញដូរមនុស្សទាំងអស់នោះទេ ដូច្នេះការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ ជារឿងសំខាន់សម្រាប់កិច្ចសហការរវាងប្រទេសពាក់ព័ន្ធនៅពេលមានបទល្មើស ដែលកើតឡើងក្នុងប្រទេសណាមួយ និងមានជនបរទេសជាជនរងគ្រោះ ឬជាជនល្មើស ។

៤. តាមសំណើឯកឧត្តម SHIN Ja Yong អនុរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ទទួលបន្ទុកកិច្ចរដ្ឋអាជ្ញា នៃសាធារណរដ្ឋកូរ៉េ ឲ្យមានអនុស្សរណៈរួមគ្នា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំបានដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយកដ្ឋានពាក់ព័ន្ធ ក្រសួងការបរទេស ក្រសួងយុត្តិធម៌ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យលើខ្លឹមសារនៃសារលិខិត និងប្រមូលទិន្នន័យ ពាក់ព័ន្ធនឹងស្ថានភាពនៃទំនាក់ទំនងវិស័យការងារ ទេសចរណ៍ និងពលករ រវាងកម្ពុជា កូរ៉េ និងសម្រេចគោរពស្នើសុំគោលការណ៍ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដើម្បីជួបពិភាក្សាជាមួយភាគីកូរ៉េ លើខ្លឹមសារសេចក្តីព្រាងអនុស្សរណៈ ដែលបានស្នើ។

៥. សាធារណរដ្ឋឥណ្ឌា បានព្រាងនូវអនុស្សរណៈថ្មីមួយ សម្រាប់កិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារពាក់ព័ន្ធនឹងការសម្របសម្រួល ក្នុងការអនុញ្ញាតឲ្យមានភាពចល័ត នៃពលរដ្ឋឥណ្ឌា រួមមានពលរដ្ឋសាមញ្ញ និស្សិត អ្នកស្រាវជ្រាវ អ្នកជំនួញ អ្នកទេសចរណ៍ អ្នកមកធ្វើការងារជាដើម នៅក្នុងប្រទេសកម្ពុជា និងពលរដ្ឋកម្ពុជា ដែលនៅក្នុងប្រទេសឥណ្ឌា រួមមានការទទួលបានសេវា សិទ្ធិក្នុងការស្នាក់នៅ និងការបញ្ជូនជនរងគ្រោះ ។ល។

ក្នុងបរិបទនេះនាងខ្ញុំពិនិត្យឃើញថា ចាំបាច់ត្រូវស្វែងរក និងប្រមូលទិន្នន័យ ពាក់ព័ន្ធនឹងពលរដ្ឋឥណ្ឌានៅកម្ពុជា និងស្ថានភាព ឬបញ្ហាផ្សេងៗ ដែលមានកន្លងមកជាមុនសិន និងពិនិត្យលទ្ធភាពក្នុងកិច្ចសហការ ដោយថ្លឹងថ្លែងលើផលប៉ះពាល់ ដែលមិនជះឥទ្ធិពលដល់សុវត្ថិភាព សន្តិសុខ

សេដ្ឋកិច្ច និងនយោបាយការបរទេស ។ នាងខ្ញុំបារម្ភថា កន្លងមកឥណ្ឌា មានអ្នកជំនាញបច្ចេកទេសខាងបង្កើត និងគ្រប់គ្រង កម្មវិធីតាមប្រព័ន្ធឌីជីថល ជាពិសេសក្នុងប្រព័ន្ធ Game Scamming យ៉ាងប៉ិនប្រសប់ និងទទួលបានប្រាក់កម្រៃខ្ពស់ ។ យើងបារម្ភថា ក្រុមនេះ អាចក្លាយជាក្រុមដែលប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា ដែលយើងមិនទាន់មានសមត្ថភាពគ្រប់គ្រងបាន ។

កន្លងមក ព្រះរាជាណាចក្រកម្ពុជា និងឥណ្ឌា ធ្លាប់មានអនុស្សរណៈ សម្រាប់បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចុះហត្ថលេខា ពីឆ្នាំ២០១៨ រួចហើយ តែមិនទាន់បានជជែកគ្នាអំពីការអនុវត្តទាល់តែសោះ ។ ដើម្បីមានមូលដ្ឋាន ក្នុងការជជែកពិភាក្សាលើអនុស្សរណៈថ្មីដែលស្នើឡើង នាងខ្ញុំសូមគោរពស្នើសុំគោលការណ៍ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង និងអង្គភាពជំនាញពាក់ព័ន្ធ រួមមាន៖ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម ជាដើម ដើម្បីត្រៀមចំណុចសំខាន់ៗសម្រាប់ពិភាក្សាសេចក្តីព្រាងអនុស្សរណៈ មុននឹងពិភាក្សាជាមួយភាគីឥណ្ឌា ។

**ទិសដៅបន្ត ៖**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៣ និងរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំបន្ត (២០២៤-២០២៨) ដោយដាក់បញ្ចូលនូវបញ្ហាជាអាទិភាព ដែលប្រឈមចំពោះមុខពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសទម្រង់ថ្មីៗ នៃបទល្មើសជួញដូរមនុស្ស ដែលផ្សារភ្ជាប់ជាមួយទម្រង់ផ្សេងទៀត នៃឧក្រិដ្ឋកម្មឆ្លងដែន និងបច្ចេកវិទ្យាព័ត៌មាន ។

អាស្រ័យដូចបានគោរពរាយការណ៍ជូនខាងលើសូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ ពុធ ១០ រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍**

ជូ_ប៊ុនអេង